# មេរៀនទី៥៖ វ័យកុមារភាពរបស់ព្រះយេស៊ូវ

## លូកា ២៖៣០-៥២

**មេរៀន** ( *យូធូបលីង* )៖ **https://youtu.be/77zpRvfHcXY**

**គោលបំណង៖** ព្រះចង់ឲ្យយើងដឹងថាព្រះយេស៊ូវពេញដោយប្រាជ្ញាដ៏អស្ចារ្យ

**ខគម្ពីរចងចាំ៖ លូកា២:៥២** *'ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើងហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង។'*

**ចំរៀង** ( *យូធូបលីង* )៖

១. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE
២. ខ្ញុំសូមលើកតម្កើងព្រះនាមទ្រង់ https://youtu.be/rPE5QOHbo70
៣. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត « ព្រះយេស៊ូវដ៏អស្ចារ្យ»

**សំភារៈត្រូវការ៖** ក្រដាស និងហ្វឹត

ក. ឲ្យក្រដាសកុមារម្នាក់១សន្លឹក ហើយឲ្យពួកគេសរសេរពាក្យថា "ព្រះយេស៊ូវ" នៅចំកណ្ដាលក្រដាស

ខ. សូមពន្យល់កុមារថាពេលខ្លះយើងរវល់ខ្លាំង ដែលធ្វើឲ្យយើងបង្វែរអ្វីដែលសំខាន់ដាក់ទៅលំដាប់ក្រោមវិញ ជាហេតុធ្វើឲ្យព្រះយេស៊ូវមិនបានស្ថិតនៅជាចម្បងក្នុងជីវិតរបស់យើងផងដែរ។



គ. សូមបង្វិលក្រដាសបញ្ច្រាស់ពីក្រោមមកលើ ហើយបត់វាតាមការណែនាំដូចនៅក្នុងរូប



ឃ. បត់វាម្ដងទៀតតាមការណែនាំ។ សូមការអត់ ទោសពីព្រះដោយការអនុញ្ញាត ឱ្យរឿងខុសក្លាយជារឿងដ៏សំខាន់បំផុត។



ង. បត់វាម្ដងទៀត។ ពេលដែលក្រដាស បត់កាន់តែតូចទៅៗ សូមពន្យល់កុមារថា ពេលដែលវត្តមានរបស់ព្រះយេស៊ូវកាន់តែ តូចទៅៗនៅក្នុងជីវិតយើងនោះយើងកំពុងតែធ្វើឲ្យព្រះមិនសប្បាយព្រះទ័យហើយ។



ច. សូមបើកក្រដាសដែលបានបត់នោះមួយផ្នត់មកវិញ រួចពន្យល់ថាប៉ុន្តែព្រះអត់ទោសឲ្យយើង ព្រោះទ្រង់ស្រឡាញ់យើង។



ឆ. បើកក្រដាសមួយផ្នត់ទៀត-នៅពេលដែលវត្តមានរបស់ព្រះកាន់តែធំឡើង នៅក្នុងជីវិតរបស់ យើងចាប់ផ្ដើមមានអារម្មណ៍រីករាយ ហើយមានសន្តិភាពនៅក្នុងចិត្ត។




ជ.សូមបើកក្រដាសបង្ហាញពាក្យព្រះយេស៊ូវដែល បានសរសេរនៅកន្លែងដែលត្រឹមត្រូវ នេះគឺជាព្រះយេស៊ូវដ៏អស្ចារ្យរបស់យើង។

## ៤. ការណែនាំមេរៀន

ព្រះគម្ពីរមិនបានប្រាប់យើងអំពីពេលវេលាក្រោយពីព្រះយេស៊ូវប្រសូត ហើយបានផ្លាស់ទៅអេហ្ស៊ីបដើម្បីលាក់ខ្លួនពីស្តេចហេរ៉ូឌជាអ្នកដែលចង់សម្លាប់ទ្រង់ជាច្រើនដងនោះទេ។ ដែលជាក់ស្តែង ភាគច្រើននៅក្នុងព្រះគម្ពីរ បាននិយាយពីពេលដែលព្រះយេស៊ូវទ្រង់ជាមនុស្សពេញវ័យទៅហើយច្រើនជាង។ ប៉ុន្តែនៅថ្ងៃនេះ យើងនឹងរៀនអំពី ហេតុការណ៍តែមួយគត់ ដែលព្រះគម្ពីរប្រាប់យើងនៅពេល ដែលព្រះយេស៊ូវនៅជាក្មេងនៅឡើយ។ តើអ្នកគិតថាព្រះយេស៊ូវ ជាក្មេងបែបណា ពេលដែលទ្រង់អាយុ១២ឆ្នាំ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរដែលយើងកំពុងមើលថ្ងៃនេះគឺ និយាយពីពេលដែលឪពុកម្តាយរបស់ព្រះយេស៊ូវ គឺយ៉ូសែប និងម៉ារាបានវង្វេងបាត់ទ្រង់។ នៅពេលព្រះយេស៊ូវអាយុ១២ឆ្នាំ ក្រុមគ្រួសាររបស់ទ្រង់បានធ្វើដំណើរ ទៅទីក្រុងយេរូសាឡិមដើម្បីថ្វាយបង្គំព្រះនៅវេលាបុណ្យរំលង។ ទោះបីជាក្រុមគ្រួសារផ្សេងទៀតមិនបានទៅយេរូសាឡិម ដើម្បីថ្វាយបង្គំនៅវេលាបុណ្យរំលងក៏ដោយ តែយ៉ូសែប និងម៉ារាគឺជាឪពុកម្តាយដែលស្មោះត្រង់នឹងព្រះ ដូចជាព្រះគម្ពីរ **លូកា ២៖៤១** បានចែងថា "រីឯមាតាបិតាទ្រង់ តែងតែទៅឯក្រុងយេរូសាឡិម នៅវេលាបុណ្យរំលង **រាល់តែឆ្នាំ**" ។ ម៉ារា និងយ៉ូសែបជាឪពុកម្តាយដ៏ល្អ ដែលត្រូវបានជ្រើសរើសឲ្យថ្វាយបង្គំដល់ព្រះជាម្ចាស់។

ព្រះគម្ពីរនិយាយថា នៅពេលដែលព្រះយេស៊ូវនៅក្នុងព្រះវិហារ ទ្រង់បានស្តាប់ និងសួរសំនួរ ទៅកាន់ពួកអាចារ្យទាំងនោះ ដោយមិនបានដឹងថាមាតាបិតារបស់ទ្រង់បានចាកចេញពីព្រះវិហារទៅផ្ទះបាត់ហើយនោះទេ។ ពួកអាចារ្យដែល នៅក្នុងព្រះវិហារមានការភ្ញាក់ផ្អើល ដោយសារតែព្រះយេស៊ូវមានការយល់ដឹងច្រើនជាងក្មេងផ្សេងៗទៀត ដែលមានអាយុស្របាលទ្រង់។ ព្រះយេស៊ូវប្រហែលជាដឹងច្រើនជាងនេះ ដែលទ្រង់អាចនឹងបង្រៀនពួកអាចារ្យ នៅទីនោះបានផងដែរ។ ពិតជាអស្ចារ្យណាស់! ទោះបីជា ទ្រង់នៅក្មេងក៏ដោយ តែព្រះយេស៊ូវយល់ដឹងច្រើនដូចពួកអាចារ្យទាំងនោះដែរ។ ព្រះយេស៊ូវគឺមិនដូចជាក្មេងឯទៀតនោះទេ។

ព្រះយេស៊ូវទ្រង់អស្ចារ្យណាស់ពីព្រោះព្រះអង្គជាព្រះ។ ព្រះអង្គទ្រង់គ្រប់លក្ខណ៍ក្នុងគ្រប់ការទាំងអស់ ហើយព្រះគម្ពីរបានប្រាប់យើងឲ្យធ្វើដូចជាព្រះយេស៊ូ ដោយយកទ្រង់ធ្វើជាគំរូរបស់យើងក្នុងរស់នៅ។ ព្រះអង្គទ្រង់អស្ចារ្យ ដោយសារទ្រង់បានធ្វើឲ្យយើងដូចជាទ្រង់ នៅពេលដែលយើងបើកចិត្តឲ្យព្រះអង្គផ្លាស់ប្តូរយើង។ ពីមួយថ្ងៃទៅមួយថ្ងៃព្រះយេស៊ូវនឹងជួយយើងឲ្យផ្លាស់ប្តូរកាន់តែដូចទ្រង់។ ហើយវាពិតជាអស្ចារ្យណាស់!

## ៦. សំនួរពិភាក្សា

១. តើនៅក្នុងសាច់រឿងនេះព្រះយេស៊ូវមានអាយុប៉ុន្មាន? ( *១២ឆ្នាំ*)

២. ហេតុអ្វីបានជាព្រះយេស៊ូវនៅក្នុងព្រះវិហារ? ( *ដើម្បីថ្វាយបង្គំព្រះនៅយេរូសាឡិមក្នុងវេលាបុណ្យរំលង* )

៣. តើព្រះយេស៊ូវកំពុងធ្វើអ្វីនៅពេលដែលមាតាបិតាទ្រង់ចាកចេញទៅផ្ទះវិញ?
(*ព្រះយេស៊ូវជជែកគ្នា ជាមួយ ពួកអាចារ្យនៅក្នុងព្រះវិហារ*)
៤. តើពួកអាចារ្យនៅព្រះវិហារមានអារម្មណ៍ដូចម្ដេចជាមួយព្រះយេស៊ូវ? (*ពួកគេមានអារម្មណ៍ភ្ញាក់ផ្អើល ជាមួយការយល់ដឹងរបស់ព្រះយេស៊ូវ*)
៥. តើព្រះយេស៊ូវអាចធ្វើអ្វីបានសំរាប់យើង? (*ព្រះយេស៊ូវអាចផ្លាស់ប្ដូរយើងឲ្យកាន់តែដូចទ្រង់*)
៦.តើកូនៗទាំងអស់គ្នាជឿទេថា ព្រះអាចប្រទានប្រាជ្ញានិងភាពក្លាហានដល់កូនៗ?
(*ចាំស/ បាទ*)

**៧. ល្បែងកំសាន្ត « តើភ្នែករបស់អ្នកអស្ចារ្យប៉ុនណា?»**
នៅក្នុងល្បែងនេះ កុមារនឹងត្រូវស្វែងរកវត្ថុមួយ ដែលគ្រូបានហៅឈ្មោះវត្ថុនោះនៅក្នុងថ្នាក់រៀន។ នរណាដែលអាចយកវត្ថុនោះមកឲ្យគ្រូបានមុនគេ គឺជាអ្នកឈ្នះ។
**សម្រាប់គ្រូ៖** សូមរៀបចំរបស់ដែលត្រូវឲ្យសិស្សរក ពីទំហំធំទៅតូច របស់ដែលមានទំហំធំអាចជាកៅអី ព្រះគម្ពីរ ក្រដាស រីឯរបស់តូចៗ អាចជា ខ្មៅដៃពណ៌លឿង ជ័រលុប ប្រដាប់ខ្ទាស់ក្រដាស ជាដើម បន្ទាប់ពីលេងល្បែងចប់ សូមពន្យល់កុមារថា យើងអាចមានការលំបាកក្នុងការស្វែងរករបស់ទាំងនោះ ប៉ុន្តែព្រះយេស៊ូវទ្រង់អស្ចារ្យណាស់ ពីព្រោះព្រះអង្គអាចស្វែងរក និងមើលឃើញនូវអ្វីៗគ្រប់យ៉ាង!

**៨. ខគម្ពីរចងចាំ**
***លូកា ២៖៥២*** *"ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង "។*

**៩. ហាត្ថកម្ម**
សូមឲ្យកុមារផាត់ពណ៌ទិដ្ឋភាពនៃក្រុងយេរូសាឡិមក្នុងវេលាបុណ្យរំលងហើយស្វែងរកព្រះយេស៊ូវ។
(តម្រុយ៖ ព្រះយេស៊ូវត្រូវបានគេរកឃើញនៅក្នុងព្រះវិហារ)

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**Pray**

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវអាចនិយាយជាមួយពួកអាចារ្យនៅក្នុងព្រះវិហារបានពេលដែលទ្រង់ទើបតែមានអាយុ១២ឆ្នាំប៉ុណ្ណោះ។ ព្រះយេស៊ូវបានបង្ហាញថាទ្រង់គឺជាព្រះ ទោះបីជាទ្រង់នៅជាក្មេងប្រុសនៅឡើយ។ ព្រះយេស៊ូវ ចង់ឲ្យយើងដូចជាទ្រង់នៅគ្រប់ការទាំងអស់។ ដូចដែលយើងបានត្រៀមខ្លួនជាស្រេចដើម្បី បង្រៀនកុមារក្នុងសប្តាហ៍នេះផងដែរ សូមចំណាយពេលរបស់អ្នកបន្តិចដើម្បីទូលសូមប្រាជ្ញា និងក្តី ស្រលាញ់ពីព្រះ ដូច្នេះអ្នកនឹងអាច ជួយដល់កុមារឲ្យពួកគេកាន់តែដូចជាព្រះអង្គ។

# សូមស្វែងរកព្រះយេស៊ូវ

